# គិលានុបដ្ឋាយិកា

តើអ្នកមានចំណាប់អារម្មណ៍ក្នុងការផ្តល់ការគាំទ្រផ្នែកសុខភាព នៅតាមសហគមន៍ដែរឬទេ? តើអ្នកចាប់អារម្មណ៍ធ្វើការដើម្បីធានាឲ្យសហគមន៍ដែលងាយរងគ្រោះ អាចចូលទៅទទួលសេវាសុខាភិបាលបានដែរឬទេ? បើអ្នកចាប់អារម្មណ៍អ្នកអាចចូលរួមជាមួយយើង!

អង្គការមិត្តសំឡាញ់ គឺជាសហគ្រាសសង្គមឈានមុខគេមួយដែលធ្វើការជាមួយកុមារ យុវវ័យ គ្រួសារ បាត់បង់ឱកាស និងសហគមន៍របស់ពួកគេ ដើម្បីជួយពួកគេឲ្យក្លាយទៅជាពលរដ្ឋឯករាជ្យ និងមានផលិទ្ធភាពសម្រាប់ប្រទេសរបស់ពួកគេ។

ក្រុមពហុជំនាញរបស់យើង រួមមានគ្រូបង្រៀន បុគ្គលិកសង្គម មន្ត្រីដាក់ការងារ អ្នកថែរក្សាកុមារ ទាំងអស់ធ្វើការជាមួយគ្នា ដើម្បីធានាថាយើងសង្គ្រោះជីវិត និងកសាងអនាគតឲ្យកុមារ យុវវ័យ គ្រួសារ និងសហគមន៍របស់ពួកគេ។

**តើអ្នកនឹងត្រូវធ្វើអ្វី?**

តួនាទី **គិលានុបដ្ឋានិកា** អ្នកនឹងក្លាយជាផ្នែកមួយនៃក្រុមការងារសង្គម ដើម្បីធានាថាកុមារ/យុវវ័យ និងគ្រួសារ ទទួលបាននូវសេវាវេជ្ជសាស្ត្រប្រកបដោយគុណភាព។

**តួនាទី នឹងការទទួលខុសត្រូវរបស់គ្រូពេទ្យមានដូចខាងក្រោម៖**

- ផ្តល់ការថែទាំសុខភាពជាមូលដ្ឋាន ដល់កុមារ យុវវ័យ និងគ្រួសាររបស់ពួកគេ នៅតាមថ្នល់ និងក្នុងសហគមន៍នៅរាជធានីភ្នំពេញ
- កសាង និងថែរក្សា បណ្តាញអ្នកផ្តល់សេវាសុខាភិបាលអោយមានភាពរឹងមាំ ដើម្បីសម្រួលដល់ការបញ្ជូនកុមារ យុវវ័យ និងគ្រួសារ ទៅកាន់សេវាដៃគូ និងធានានូវការត្រួតពិនិត្យយ៉ាងទៀងទាត់នៃសេវាកម្មរបស់ពួកគេ
- ផ្តល់ការបណ្តុះបណ្តាល និងការគាំទ្រ ដល់ក្រុម ដើម្បីផ្តល់ការថែទាំសុខភាពជាមូលដ្ឋាន ដល់កុមារ និងយុវជន និងគ្រួសាររបស់ពួកគេ
- ផ្តល់សេវាកាត់បន្ថយគ្រោះថ្នាក់ដល់អ្នកប្រើគ្រឿងញៀន
- ត្រួតពិនិត្យ និងវាយតម្លៃស្ថានភាពអនាម័យនៃតំបន់ការងារ និងមជ្ឈមណ្ឌល
- រក្សាទំនាក់ទំនងល្អជាមួយភ្នាក់ងាររដ្ឋាភិបាល ដៃគូនានា និងអ្នកផ្តល់សេវាសុខាភិបាលផ្សេងៗទៀត
- ទុកដាក់ និងថែរក្សាឲ្យបានត្រឹមត្រូវនូវសម្ភារៈវេជ្ជសាស្ត្រ (ថ្នាំពេទ្យ ស្រោមអនាម័យ សឺរាំង ម្ជុល)
- ត្រួតពិនិត្យវាយតំលៃសុខភាពអតិថិជនពេលមានតំរូវការ
- ត្រួតពិនិត្យបញ្ជីស្តុកថ្នាំជាប្រចាំ និង ប្រាកដថារាល់ថ្នាំដែលប្រើប្រាស់មានសុពលភាពប្រើប្រាស់ត្រឹមត្រូវ ។

**ល័ក្ខខ័ណ្ឌជ្រើសរើស:**

- អ្នកគឺជាបុគ្គលស្វាហាប់ អ្នកពូកែធ្វើការងារជាក្រុមនិងមានភាពឯករាជ្យ
- អ្នកចូលចិត្តធ្វើការជាមួយកុមារ និងយុវវ័យ
- អ្នកមានបទពិសោធន៍ក្នុងការផ្តល់សេវាសុខភាព និងការថែទាំ
- អ្នកមានឥរិយាបថរួសរាយរាក់ទាក់ ហើយអ្នកចូលចិត្តធ្វើការជាមួយអ្នកជំងឺ
- អ្នកមានចំនេះដឹងអំពីជំងឺកាមរោគ អេដស៍ សុខភាពបន្តពូជ និងអាហារូបត្ថម្ភ(កាន់តែប្រសើរ)
- មានចំណង់ចំណូលចិត្តធ្វើការតាមសហគមន៍ក្រីក្រ
- ជាមនុស្សបត់បែនបានតាមកាលៈទេសៈ
- មានសញ្ញាប័ត្រគិលានុបដ្ឋ (Nurse)
- មិនមែនជាបុគ្គលិកក្របខ័ណ្ឌរដ្ឋ

**ទីតាំងការងារ:** ភ្នំពេញ

បេក្ខជនទាំងពីរភេទដែលមានចំណាប់អារម្មណ៍ សូមផ្ញើរនូវប្រវត្តិរូបសង្ខេប (CV និង Cover Letter) មកទីស្នាក់ការអង្គការមិត្តសំឡាញ់ អាសយដ្ឋានផ្ទះលេខ២១៥ ផ្លូវលេខ១៣ ខាងជើងសារៈមន្ទីរជាតិ ឬ E-mail: hr@mithsamlanh.org ។ ព័ត៌មានបន្ថែមអាចទំនាក់ទំនងបានតាមរយៈទូរស័ព្ទ ០២៣ ២២០ ៥៩៦

អង្គការមិត្តសំឡាញ់ ផ្តល់នូវភាពយុត្តិធម៌ដល់អ្នកដាក់ពាក្យទាំងអស់។ បេក្ខជនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងត្រូវទំនាក់ទំនងដើម្បីធ្វើការសម្ភាសន៍។ ស្ត្រីត្រូវបានលើកទឹកចិត្ត។

**អង្គការមិត្តសំឡាញ់គោរពតាមគោលការណ៍ការពារកុមារ។**
**ទទួលពាក្យចាប់ពីថ្ងៃជូនដំណឹងនេះ រហូតដល់ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២១។**